D119556 DC-Cam

# របាយការណ៍ស្តីពី
# ទីតាំងរណ្តៅសាកសពនៅស្រុកពញាក្រែក

ភូមិស៊ីងតូច ឃុំកក់

រណ្តៅសាកសពទំហំប្រហែល៣ម៉ែត្រការេចំនួនពីរ បច្ចុប្បន្នស្ថិតនៅខាងក្រោយប៉ុស្តិ៍នគរបាលឃុំកក់ ស្រុកពញាក្រែក ប្រហែល៥ម៉ែត្រប៉ុណ្ណោះ ។ មានរណ្តៅសាកសពចំនួន១ផ្សេងទៀតស្ថិតនៅចម្ងាយ ប្រហែល២០ម៉ែត្រពីរណ្តៅទាំងពីរខាងលើ ។

ខាងក្រោមនេះជាការរៀបរាប់របស់សាក្សីឃើញហេតុការណ៍ និងសាក្សីប្រយោល

ង៉ែត សំអឿន ជាប៉ូលិសប្រចាំឃុំកក់ និយាយថាជុំវិញបរិវេណមន្ទីរប៉ុស្តិ៍របស់គាត់ មានរណ្តៅសាកសពច្រើន ហើយរណ្តៅនីមួយៗពុំទាន់មាននរណាមកគាស់ឡើយ ។ សំអឿន បានធានាចំពោះការជីក
គាស់របស់ក្រុមធ្វើកោសល្យវិច្ច័យឆ្អឹងថានឹងជួបប្រទះគ្រោងឆ្អឹងដែលមានសភាពដើម ។

សុខ គន់ អាយុ៥១ឆ្នាំ បច្ចុប្បន្នជាគ្រូបង្រៀននៅសាលាបឋមសិក្សាឃុំដូនតី គឺជាអតីតជនរងគ្រោះដែលត្រូវខ្មែរក្រហមនាំយកទៅសម្លាប់នៅរណ្តៅដែលជីកស្រាប់នៅក្រោយប៉ុស្តិ៍នគរបាលប្រចាំឃុំកក់ ។ គន់ បានរៀបរាប់ថា កាលពីអំឡុងឆ្នាំ១៩៧៥-៧៧ គាត់គឺជាកម្មាភិបាលបម្រើការនៅពាណិជ្ជកម្ម ឃុំដូនតីខាងកើត ។ លុះមកដល់ឆ្នាំ១៩៧៨ គាត់ត្រូវខ្មែរក្រហមភូមិភាគនិរតីចាប់គាត់យកទៅសម្លាប់ ។ គន់ គឺជាមនុស្សពិការម្រាមដៃទាំងសងខាង និងកំបុតប្រអប់ជើងឆ្វេងម្ខាងតាំងពីកំណើត ។ គន់ ត្រូវបាន ចាប់ខ្លួននៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ ជាមួយប្រជាជនក្នុងភូមិសំបូរ (បច្ចុប្បន្នភូមិទំនប់)ទាំងអស់ យក ទៅសម្លាប់នៅភូមិស៊ីងតូច ឃុំកក់ ភូមិឡ ឃុំកោងកាង និងនៅត្រពាំងឫស្សី ឃុំកក់ ។ មូលហេតុនៃការ ចាប់នេះ គន់ បានរៀបរាប់ថា មកពីខ្មែរក្រហមខាងនិរតីចោទប្រកាន់ថាជាខ្សែស្រឡាយជាមួយនឹង ប្រធានភូមិភាគបូព៌ា សោភឹម ហៅ ម៉ឹយ ហៅ សុវណ្ណ ព្រោះទីតាំងឃុំដូនតី គឺជាអតីតបន្ទាយដ៏រឹងមាំ របស់សោភឹម ។

គន់ ត្រូវខ្មែរក្រហមខាងភូមិភាគនិរតីចំនួនពីរនាក់ដែលមានអាយុប្រហែល២០ឆ្នាំ វាយនឹងដំបងពី លើក្បាលប៉ែកខាងក្រោយទម្លាក់ក្នុងរណ្តៅ ។ គន់ បន្ថែមថា ពេលដែលគាត់ធ្លាក់ទៅក្នុងរណ្តៅហើយ កម្មាភិបាលទាំងពីរនាក់បានចុះទៅវាយគាត់បន្ថែមទៀតចំចិញ្ចើមខាងឆ្វេង (មានស្នាមរហូតដល់សព្វថ្ងៃ) ។ គន់ គឺជាជនរងគ្រោះទី២៨ដែលត្រូវសម្លាប់ទម្លាក់រណ្តៅ ។ បន្ទាប់ពី គន់ សន្លប់បាត់ស្មារតី ខ្មែរក្រហមបាន វាយមនុស្សជាច្រើនទៀតទម្លាក់ពីលើ ។ រយៈពេលក្រោយមក គន់ បានដឹងខ្លួន ហើយបានវារចេញពីរណ្តៅ មកខាងក្រៅទៅពួននឹងគុម្ពឈើមួយកំបាំងពីភ្នែកខ្មែរក្រហម ។ ពេលដែល

គន់ វារចេញ គឺចំចន្លោះពេល ដែលខ្មែរក្រហមចេញទៅដឹកជញ្ជូនមនុស្សមកសម្លាប់ទៀត ។ រយៈពេលបីថ្ងៃក្រោយមក ទើប គន់ បានវារមកដល់ភូមិ ហើយបានប្រាប់ដល់ប្រជាជនដែលជាខ្មែរស្រឡាយខាងសោភីមទាំងអស់ពិសភាព ការណ៍ដែលបានកើតមកលើរូបគាត់ ។ យ៉ែម យុទ្ធ ជាអ្នកដែលបានជួយសង្គ្រោះ គន់ ដោយផ្ទាល់ ។ បច្ចុប្បន្ន យុទ្ធ គឺជាប៉ូលិសប្រចាំឃុំដូនតីដែរ ។ គន់ មិនបានចាំរណ្តៅដែលខ្មែរក្រហមវាយគាត់ទម្លាក់នោះ ទេ ប៉ុន្តែគាត់ចំណាំបានថា មានរណ្តៅច្រើនណាស់ដែលស្ថិតនៅជុំវិញរណ្តៅដែលខ្មែរក្រហមវាយគាត់ ។ គន់ បាននិយាយទៀតថា ប្រពន្ធ និងកូនរបស់គាត់ពីរនាក់ទៀត ត្រូវខ្មែរក្រហមសម្លាប់នៅក្នុងរណ្តៅតែ មួយជាមួយគាត់ ។

យាក់ អៀម បច្ចុប្បន្នមានទីលំនៅភូមិទំនប់ ឃុំដូនតី រួមជាមួយកូនបង្កើតពីរនាក់ទៀតគឺ អូន និង ពៅ ត្រូវខ្មែរក្រហមខាងភូមិភាគនិរតីដឹកតាមរថយន្តធំៗយកទៅសម្លាប់នៅភូមិស៊ីងតូចដែរ ប៉ុន្តែត្រូវ បានដោះលែងមកវិញបន្ទាប់ពីស៊ើបសួរដឹងថា អៀម មានកូនប្រុសម្នាក់កំពុងបម្រើការនៅកងទ័ពជ្សីម ។ កូនប្រុសរបស់ អៀម ដែលធ្វើទ័ពនោះ ត្រូវជាមិត្តភក្រ័ជាមួយនឹងឃាតករដែលប្រុងនឹងសម្លាប់គាត់ ទម្លាក់រណ្តៅ ។ ប្តីរបស់ អៀម ត្រូវខ្មែរក្រហមនាំយកទៅសម្លាប់មុនការនាំគាត់ទៅមួយថ្ងៃ ។ បច្ចុប្បន្នកូន ស្រីរបស់គាត់ឈ្មោះ អូន មានអាយុ៣៣ឆ្នាំហើយ និងកូនប្រុសរបស់គាត់ឈ្មោះ ពៅ ក៏មានអាយុ ប្រហែលនឹង អូន ដែរ ។ អូន បាននិយាយធ្វើគ្រាប់តាមខ្មែរក្រហមទាំងពីរនាក់ថា “ពួកវានេះសុទ្ធតែជាកូន ចៅរបស់អាភីម (សោភីម) ” ។ អូន កាលនោះមានអាយុ១១ឆ្នាំ ។ គាត់បានឃើញមានរណ្តៅសាកសព ច្រើនណាស់នៅក្នុងបរិវេណព្រៃភូមិស៊ីងតូច ប្រមទាំងឃើញមានសុទ្ធតែឈាមនៅពាសពេញដីទៀតផង ។

អ៊ឹម ញ៉ែម គឺជាកូនប្រុសរបស់ យាក់ អៀម ដែលត្រូវខ្មែរក្រហមនាំយកទៅសម្លាប់ជាមួយគ្នា ប៉ុន្តែជិះឡានខុសគ្នា ក៏បាននិយាយដូច្នេះថា “ខ្ញុំត្រូវខ្មែរក្រហមចាប់ចងនឹងខ្សែអង្រឹង និងចងមុខនឹង ក្រមាដែលច្រៀកជាពីរបីកំណាត់នាំយកទៅកាន់រណ្តៅប្រុងសម្លាប់ ប៉ុន្តែពេលនោះ ត្រូវប្រធានកងរបស់ ខ្មែរក្រហមម្នាក់មិនស្គាល់ឈ្មោះបានស្រែកឲ្យកងឈ្លបដែលជាឃាតករឈប់សិន ហើយក៏នាំយកគាត់មក កាន់កន្លែងមួយឆ្ងាយពីទីតាំសម្លាប់ ព្រមទាំងបានប្រាប់ថា “នេះជាសំណាងរបស់ឯងហើយ ព្រោះឯងមាន បងប្រុសធ្វើកងទ័ពនៅមជ្ឈិម” ។ ស្ថិតក្នុងសភាពរុំមុខ គាត់បានឮសូរសម្រែកស្រ្តីរងគ្រោះស្រែកនៅពេល ដែលខ្មែរក្រហមវាយទម្លាក់រណ្តៅ ។

ភូមិឡ ឃុំកោងកាង

នៅក្នុងភូមិឡ មានអណ្តូងទឹកចំនួន៥ ដែលខ្មែរក្រហមប្រើប្រាស់ជាទីតាំងសម្លាប់មនុស្ស ហើយរហូតមកដល់សព្វថ្ងៃនេះ ពុំទាន់មាននរណាគាស់នៅឡើយទេ ។ រឿងរ៉ាវទាក់ទងនឹងការសម្លាប់មនុស្សនេះ ត្រូវបានសាក្សីមួយចំនួននិយាយប្រាប់ដូច្នេះថាៈ

នៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៧ អ្នកស្រុកភូមិឡ បានរស់នៅជាធម្មតា ប៉ុន្តែចាប់ពីឆ្នាំ១៩៧៨ មក ប្រជាជនភូមិឡទាំងអស់បានត្រូវជម្លៀសឲ្យទៅរស់នៅក្នុងទឹកដីស្រុកស្ទោង ខេត្តកំពង់ធំ និងស្រុក កញ្ជ្រៀច ខេត្តព្រៃវែង ។ អ៊ុម ទឹម ជាអតីតប្រជាជនមូលដ្ឋានរស់នៅក្បែរភូមិឡ ជាអ្នកបានឃើញដោយផ្ទាល់នូវសាកសពដែលទើបតែសម្លាប់ថ្មីៗដាក់អណ្តូង នៅពេលដែលគាត់បានដើរមករកបន្លែសម្រាប់សហករណ៍ ។ ទឹម និយាយថា ពេលដែលខ្មែរក្រហមសម្លាប់មនុស្ស គឺពុំមានការអនុញ្ញាតិឲ្យមានមនុស្សណាម្នាក់ដើរឆ្លងកាត់ឡើយ ។ ទឹម បន្ថែមថា ក្រោយពីការជម្លៀសរបស់ខ្មែរក្រហម ផ្ទះរបស់អ្នកស្រុកត្រូវរឹបអូសយកធ្វើជាមន្ទីរឃុំឃាំងបណ្តោះអាសន្ន និងខ្លះត្រូវរុះរើយកធ្វើអុសដុត ។

អណ្តូងទឹកតាខាំ ឬ អន្លូងទឹកតាឆាយ

តាឆាយ គឺជាម្ចាស់អណ្តូងទឹកកាលពីមុនរបបខ្មែរក្រហមមកកាន់កាប់ ប៉ុន្តែបច្ចុប្បន្នអណ្តូងនេះត្រូវធ្លាក់ទៅលើឈ្មោះ ខាំ សារ៉ាយ ទៅវិញ ។ តាឆាយ គឺជាអ្នកបានឃើញសាកសពនៅក្នុងអណ្តូងនេះ តាំងពីពេលសម្លាប់បានចាប់ផ្តើមលើកទី១ និងបានឃើញម្តងទៀតនៅលើកទី២ គឺមានសាកសពពេញ ប្រហបទៅហើយ ។ ប៉ុន្តែគាត់ពុំបានឃើញការសម្លាប់ដោយផ្ទាល់ទេ ។ តាឆាយ បានសន្និដ្ឋានថា ជនរងគ្រោះមានខ្លះជាកងចល័ត និងខ្លះទៀតជាទាហានបូព៌ា ។ សារ៉ាយ បន្ថែមថា គាត់ឃើញមានស្នាមឈាមនៅពាសពេញមាត់អណ្តូងនៅពេលដែលគាត់ចូលមកកាន់ផ្ទះនៅឆ្នាំ១៩៧៩ ។ អណ្តូងទឹកនេះត្រូវម្ចាស់ផ្ទះថែ រក្សាទុករហូតមិនឲ្យមានការគាស់កកាយទេ ។ ប៉ុន្តែនៅពេលដែលមានការសុំជីកគាស់នោះ គាត់បាន និយាយថា គាត់ពុំមានជំទាស់អ្វីឡើយ តែចាំបាច់ត្រូវធ្វើឡើងតាមប្រពៃណីគឺ សូត្រមន្តបង្សុកូលឲ្យបាន ត្រឹមត្រូវ ហើយការចំណាយលើបញ្ហានេះ គឺជាបន្ទុករបស់ក្រុមការងារ ។

អណ្តូងយាយ យ៉ាត់

យាយ យ៉ាត់ គឺជាម្ចាស់អណ្តូងនេះ ហើយបច្ចុប្បន្នស្ថិតនៅក្រោយទ្រុងជ្រូករបស់គាត់ ។ យ៉ាត់ និយាយថា អណ្តូងរបស់គាត់នេះប្រហែលជាមានសម្លាប់ភាគច្រើនជានារីហើយ

ព្រោះនៅពេលដែលគាត់ ត្រឡប់ចូលមកកាន់ផ្ទះរបស់គាត់វិញកាលពីឆ្នាំ១៩៧៩ គាត់បានឃើញមានស្បៀតសក់ ក្រមាំ និងប្រដាប់ ប្រើប្រាស់របស់ស្ត្រីមួយចំនួនទៀត ព្រមទាំងមានឈាមពាសពេញផង ។ គុន សាវិន ជាកូនស្រីរបស់ យ៉ាត់ បានប្រាប់ថា គាត់បានឃើញនៅក្នុងអណ្តូងមានពពុះដូចទឹកដាំពុះ ប៉ុន្តែធាតុពិតគឺជាសាកសពដែលហើម និងរលួយខ្លាំងមែនទែន ។ សាវិន ខស្សព្រាហ៍យល់សប្តិឃើញអាក្រក់ៗណាស់ ដូចជាឃើញសាកសពដែលនៅ ក្នុងអណ្តូងនោះងើបមកប្របាច់កគាត់ជាដើម ។ យាយ យ៉ាត់ បានស្នើសុំឲ្យក្រុមការងារជួយបេញលុយកាក់ ខ្លះដើម្បីធ្វើពិធីបង្សុកូនជូនវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ក្នុងអណ្តូងនេះ នៅពេលដែលមានការជីកគាស់របស់ក្រុមធ្វើកោសល្យវិច័យ ។

អណ្តូងយាយ ញ៉ូ

ញ៉ូ គឺជាម្ចាស់អណ្តូងទឹកដែលខ្មែរក្រហមសម្លាប់មនុស្សដាក់ ។ បច្ចុប្បន្នអណ្តូងទឹកនេះត្រូវគាត់ដាំ ដើមល្ហុងចំនួន១ដើមពីលើ និងចាក់សំរាមបំពេញបន្ថែមភាពក្រហេងក្រហូង ។ ញ៉ូ បាននិយាយដូច្នេះថា សាកសពដែលកប់នៅក្នុងអណ្តូងរបស់គាត់ ពុំបានធ្វើឲ្យគាត់ខ្លាចឡើយ ហើយព្រមទាំងធ្វើឲ្យគាត់មាន ជំនឿថាបានប្រាប់លេខឆ្នោតគាត់ជាច្រើនលើកទៀតផង ។ នៅពេលថ្មីៗបន្ទាប់ពីថ្ងៃរំដោះខែមករា ឆ្នាំ ១៩៧៩ ញ៉ូ ខស្សព្រាហ៍យល់សប្តិឃើញខ្មោចដែលនៅក្នុងអណ្តូងរបស់គាត់លូកដៃចេញពីអណ្តូងមកសុំបាយ គាត់ហូប និងឃើញចេញពីអណ្តូងមកទាំងហ្វូងមកសុំបាយគាត់ ។ ញ៉ូ បន្ថែមថា សាកសពទាំងអស់នេះមានភាគច្រើនបំផុតគឺជាទាហានរបស់ភូមិភាគបូព៌ា ព្រោះក្នុងសុបិន្តរបស់គាត់ឃើញសុទ្ធតែបុរសដែលស្លៀកតែខោខ្លីមួយប៉ុណ្ណោះ ។ ញ៉ូ បានប្រាប់ថា ទាហានដែលត្រូវសម្លាប់គឺសុទ្ធតែត្រូវដោះសម្លៀកបំពាក់ ចេញទាំងអស់ ។ កូនប្រុសរបស់ ញ៉ូ ម្នាក់ត្រូវគាត់អះអាងថាជាខ្មោចដែលកប់ក្នុងអណ្តូងរបស់គាត់មកសុំ នៅជាមួយ ។ ចំពោះអណ្តូងមួយនេះម្ចាស់ផ្ទះពុំបានទាមទារអ្វីឡើយ គឺសុខចិត្តឲ្យក្រុមការងារគាស់មើល ដោយមិនបានហាមឃាត់ឡើយ ។

នៅមានអណ្តូងចំនួនពីរទៀត ដែលស្ថិតនៅជិតផ្ទះរបស់ ញ៉ូ គឺប្រហែល៧ម៉ែត្រប៉ុណ្ណោះ ។ ញ៉ូ បាន អះអាងចំពោះរឿងរ៉ាវគ្រប់យ៉ាងថា មានការជាប់ពាក់ពន្ធ័ដូចគ្នានឹងអណ្តូងដែលស្ថិតនៅក្រោយផ្ទះរបស់ គាត់ដែរ ព្រោះគាត់បានឃើញមានខ្សែអគ្គីសនីជាច្រើនដុំស្ថិតនៅរាយប៉ាយតាំងពីអណ្តូងរបស់គាត់រហូតដល់អណ្តូងដែលនៅជិតនោះ ។